**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២៣៤ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការបង្កើតគណៈកម្មាធិការដឹកនាំការងារអតិថិជនខ្នាតទីតាំងហិរញ្ញវត្ថុ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពី ការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពី ការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



www.pheakdeylaw.com

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

**"គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ"** សរសេរអក្សរកាត់ថា "គ.អ.ហ" ត្រូវបានបង្កើតឡើងជាសេនាធិការមួយរបស់ **គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ។

**មាត្រា ២.-**

ការបង្កើត "គ.អ.ហ" មានគោលដៅជំរុញ និងធានាឱ្យបាននូវការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ប្រកបដោយភាពរឹងមាំ និងស្ថិរភាព ។

**មាត្រា ៣.-**

"គ.អ.ហ" មានតួនាទីជាសេនាធិការរបស់ **គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ក្នុងការអនុវត្តការងារដូចខាងក្រោម ÷

- ដឹកនាំ សម្របសម្រួល តាមដាន និងត្រួតពិនិត្យការអនុវត្តផែនការសកម្មភាពនៃ "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ" របស់រាជរដ្ឋាភិបាល ។
- រៀបចំ និងធ្វើបច្ចុប្បន្នកម្ម **"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ"** តាមការចាំបាច់ ។
- ផ្តួចផ្តើម និងដាក់ចេញនូវវិធានការសមស្រប ដើម្បីជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ឆ្លើយតបទៅនឹងគោលបំណងរបស់ **"យុទ្ធសាស្ត្រចតុកោណ"** និង **"ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ"** របស់រាជរដ្ឋាភិបាល ។
- សម្របសម្រួល និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ សម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ។
- អនុវត្តកិច្ចការផ្សេងទៀត តាមការចង្អុលបង្ហាញរបស់ **គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** និងរបស់រាជរដ្ឋាភិបាល ។/



www.pheakdeylaw.com

## ជំពូកទី ២
## សមាសភាព និង រចនាសម្ព័ន្ធ

**មាត្រា ៤.-**

គ.អ.ហ មានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១- | ទេសាភិបាល ធនាគារជាតិនៃកម្ពុជា | ប្រធាន |
| ២- | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- | ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា | អនុប្រធានប្រចាំការ |
| ៤- | រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៥- | រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៦- | រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៧- | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨- | អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩- | អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា | សមាជិក |
| ១០- | អគ្គលេខាធិការ ធនាគារជាតិនៃកម្ពុជា | លេខាធិការ ។ |

សមាសភាពជាក់ស្ដែងនៃ គ.អ.ហ ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៥.-**

ដើម្បីបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន ដូចមានចែងក្នុងមាត្រា៣ អនុក្រឹត្យនេះ ប្រកបដោយប្រសិទ្ធភាព ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ប្រធាន គ.អ.ហ ត្រូវបង្កើត **“ក្រុមការងារបច្ចេកទេស”** មួយដែលដឹកនាំដោយតំណាងធនាគារជាតិនៃកម្ពុជា ដើម្បីជំរុញការអនុវត្ត **“យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ”** និងភារកិច្ចផ្សេងទៀតតាមការណែនាំរបស់ គ.អ.ហ ។

សមាសភាពនៃ **“ក្រុមការងារបច្ចេកទេស”** ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់ **គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ។



www.pheakdeylaw.com

## ជំពូកទី ៣
## ដំណើរការការងារ

**មាត្រា ៦.-**

គ.អ.ហ ត្រូវរៀបចំប្រជុំយ៉ាងតិច ៣ដងក្នុងមួយឆ្នាំ និង/ឬ តាមការចាំបាច់ និងត្រូវរាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពអភិវឌ្ឍវិស័យហិរញ្ញវត្ថុជូន **គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ។

**មាត្រា ៧.-**

តាមការអញ្ជើញរបស់ប្រធាន អនុប្រធាន សមាជិក និងលេខាធិការនៃ គ.អ.ហ ត្រូវចូលរួមប្រជុំ ឬចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចជំនួស ដើម្បីចូលរួមប្រជុំក្នុងករណីអវត្តមាន ឬមានធុរៈ ។

**មាត្រា ៨.-**

គ.អ.ហ មានសិទ្ធិអញ្ជើញមន្ត្រីផ្សេងៗទៀតនៃក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធចូលរួមការងារបាន ។

គ.អ.ហ មានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន និងភាគីពាក់ព័ន្ធផ្សេងទៀត ចូលរួមប្រជុំ តាមការចាំបាច់ ។

**មាត្រា ៩.-**

គ.អ.ហ មានលេខាធិការដ្ឋានមួយនៅធនាគារជាតិនៃកម្ពុជា ជាសេនាធិការ សម្រាប់បំពេញមុខងាររបស់ខ្លួន ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន គ.អ.ហ ត្រូវកំណត់ដោយប្រកាសរបស់ទេសាភិបាលធនាគារជាតិនៃកម្ពុជា ដែលជាប្រធាន គ.អ.ហ ។

គ.អ.ហ មានសិទ្ធិប្រើប្រាស់ត្រារបស់ធនាគារជាតិនៃកម្ពុជាសម្រាប់ដំណើរការការងាររបស់ខ្លួន ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។



www.pheakdeylaw.com

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាប

ជូនសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com